# នៅចំពោះមុខការិយាល័យសហចៅក្រមស៊ើបអង្កេត
# នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 01-Apr-2016, 15:10
CMS/CFO: Sann Rada

## <u>ព័ត៌មានពិស្តារនៃការដាក់ឯកសារ</u>

| | | |
|---|---|---|
| **សំណុំរឿងលេខ** | : | ០០៤/០៧-០៩-២០០៩-អវតក/កសចស |
| **ដាក់ទៅ** | : | ការិយាល័យសហចៅក្រមស៊ើបអង្កេត |
| **ថ្ងៃដាក់** | : | ថ្ងៃទី១ ខែមេសា ឆ្នាំ២០១៦ |
| **ភាគីអ្នកដាក់** | : | សហព្រះរាជអាជ្ញាអន្តរជាតិ |
| **ភាសាដើម** | : | អង់គ្លេស |

## <u>ចំណាត់ថ្នាក់ឯកសារ</u>

**ប្រភេទឯកសារដែលស្នើឡើងដោយភាគីដាក់ឯកសារ:** សម្ងាត់

**ចំណាត់ថ្នាក់ឯកសារកំណត់ដោយ កសចស:** សម្ងាត់/Confidential

**ប្រភេទនៃចំណាត់ថ្នាក់ឯកសារ:**

**ការពិនិត្យឯកសារបណ្តោះអាសន្នឡើងវិញ:**

**ឈ្មោះមន្ត្រីដែលបានពិនិត្យ:**

**ហត្ថលេខា:**

---

## ចម្លើយតបរបស់សហព្រះរាជអាជ្ញាអន្តរជាតិ នៅនឹងសំណើសុំបំពេញកិច្ចស៊ើបសួរ របស់ដើមបណ្តឹងរដ្ឋប្បវេណី ទាក់ទងនឹងឧក្រិដ្ឋកម្មស្តីពី ការមានផ្ទៃពោះដោយបង្ខំ

---

<u>**អ្នកដាក់ឯកសារ:**</u>

**សហព្រះរាជអាជ្ញាអន្តរជាតិ**

លោក Nicholas KOUMJIAN

<u>**ចម្លងជូន:**</u>

**សហព្រះរាជអាជ្ញាជាតិ**

លោកស្រី ជា លាង

<u>**អ្នកទទួលឯកសារ:**</u>

**សហចៅក្រមស៊ើបអង្កេត**

ចៅក្រម យូ ប៊ុនឡេង

ចៅក្រម Michael BOHLANDER

**មេធាវីដើមបណ្តឹងរដ្ឋប្បវេណី ក្នុងសំណុំរឿង០០៤ ទាំងអស់**

**សហមេធាវី អោ អាន**

លោក មុំ លុជ្ស

លោក Göran SLUITER

លោក Richard ROGERS

**សហមេធាវី យីម ទិត**

លោក សូ មូស្សេទ្នី

លោកស្រី Suzana TOMANOVIC

## I. សេចក្តីផ្តើម

១. សហព្រះរាជអាជ្ញាអន្តរជាតិ ("សពអ") ឆ្លើយតបទៅនឹងសំណើសុំឲ្យបំពេញកិច្ចស៊ើបសួររបស់ដើមបណ្តឹងរដ្ឋប្បវេណីពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មស្តីពីការមានផ្ទៃពោះដោយបង្ខំ ("សំណើសុំឲ្យបំពេញកិច្ចស៊ើបសួរ")[1]។ នៅក្នុងសំណើសុំឲ្យបំពេញកិច្ចស៊ើបសួររបស់គាត់ ដើមបណ្តឹងរដ្ឋប្បវេណីជម្រុញ ឲ្យការិយាល័យសហចៅក្រមស៊ើបអង្កេត ("កសចស") ស្វែងរកថា ការមានផ្ទៃពោះដោយ បង្ខំ ស្ថិតនៅក្នុងនិយមន័យនៃ "អំពើអមនុស្សធម៌ផ្សេងៗទៀត" នៃឧក្រិដ្ឋកម្មនានាប្រឆាំងនឹងមនុស្សជាតិ ដែលត្រូវបានដាក់ទណ្ឌកម្មដោយមាត្រា៥ នៃច្បាប់ស្តីពីការបង្កើតឲ្យមាន អវតក ("ច្បាប់ អវតក")[2]។ បន្ថែមលើនេះ ដើមបណ្តឹងរដ្ឋប្បវេណីអះអាងថា ធាតុផ្សំនានានៃការមានផ្ទៃពោះដោយបង្ខំជា "អំពើអមនុស្សធម៌ផ្សេងៗទៀត" គឺដូចគ្នាសុទ្ធសាធទៅនឹងធាតុផ្សំនានានៃឧក្រិដ្ឋកម្មស្តីពី "ការមានផ្ទៃពោះដោយបង្ខំ" ដែលបានផ្តល់និយមន័យនៅក្នុងមាត្រា៧(២)(ច) នៃលក្ខន្តិកៈទីក្រុងរ៉ូមនៃតុលាការព្រហ្មទណ្ឌអន្តរជាតិ ("លក្ខន្តិកៈទីក្រុងរ៉ូម")[3]។

២. កសព គាំទ្រសំណើរបស់ដើមបណ្តឹងរដ្ឋប្បវេណីសុំឲ្យស៊ើបសួរបន្ថែមអំពីអង្គហេតុនានា ថាតើស្ត្រី និង ក្មេងស្រី ត្រូវបានបង្ខំ ឬបង្ខិតបង្ខំឲ្យមានផ្ទៃពោះនៅក្នុងអំឡុងពេលនៃរបបកម្ពុជាប្រជាធិបតេយ្យ ដោយមកពីទំនាក់ទំនងរវាងការធ្វើឲ្យមានផ្ទៃពោះដោយបង្ខំ និងគោលនយោបាយរបស់កម្ពុជា ប្រជាធិបតេយ្យពាក់ព័ន្ធនឹងសេចក្តីណែនាំស្តីពីអាពាហ៍ពិពាហ៍ ហើយនិង អំពីវិបាកនៃការធ្វើឲ្យមានផ្ទៃពោះដោយបង្ខំ មាននៅលើការរងទុក្ខរបស់ស្ត្រី និងក្មេងស្រី។

៣. យ៉ាងណាក៏ដោយ ដូចដែលបានពិភាក្សាលំអិតនៅខាងក្រោម សពអ សូមស្នើថា និយមន័យនៃឧក្រិដ្ឋកម្មស្តីពីការមានផ្ទៃពោះដោយបង្ខំនៃលក្ខន្តិកៈទីក្រុងរ៉ូម មិនឆ្លុះបញ្ចាំងនូវច្បាប់ ទំនៀមទម្លាប់អន្តរជាតិ នៅក្នុងឆ្នាំ១៩៧៥ នោះទេ។ ផ្ទុយទៅវិញ សពអ សូមជូនសេចក្តីសន្និដ្ឋានថា ច្បាស់ណាស់ នៅឆ្នាំ១៩៧៥ វាត្រូវបានគេទទួលស្គាល់ថា ការបង្ខំ ឬការបង្ខិតបង្ខំ ស្ត្រី និងក្មេងស្រីឲ្យ

---

[1] **D301** សំណើរបស់មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីសុំឲ្យមានកិច្ចស៊ើបសួរប្រឆាំង អោ អាន និង យឹម ទិត្យ ពាក់ព័ន្ធនឹងឧក្រិដ្ឋកម្មមានផ្ទៃពោះដោយបង្ខំ, ៤ មីនា ២០១៦ ("សំណើសុំបំពេញកិច្ចស៊ើបសួរ")។ អសព មិនជំទាស់ទៅនឹងសំណើសុំបន្ថែមចំនួនទំព័រកំណត់របស់ដើមបណ្តឹងរដ្ឋប្បវេណីទេ។

[2] ច្បាប់ស្តីពី ការបង្កើតឲ្យមានអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ, បានប្រកាសឲ្យប្រើនៅថ្ងៃទី២៧ ខែតុលា ឆ្នាំ២០០៤ ("ច្បាប់ អវតក")។

[3] លក្ខន្តិកៈទីក្រុងរ៉ូមនៃតុលាការព្រហ្មទណ្ឌអន្តរជាតិ, អនុម័តនៅថ្ងៃទី១៧ ខែកក្កដា ឆ្នាំ១៩៩៨, ចូលជាធរមាននៅថ្ងៃទី១ ខែកក្កដា ឆ្នាំ២០០២ ("លក្ខន្តិកៈទីក្រុងរ៉ូម")។

មានផ្ទៃពោះដោយប្រឆាំងនឹងឆន្ទៈរបស់ពួកគាត់ នៅក្នុងអំឡុងពេលនៃបរិបទនៃការវាយប្រហារដ៏ទូលំទូលាយ ឬ ដោយប្រព័ន្ធ សំដៅប្រឆាំងនឹងជនជាតិស៊ីវិល គឺបំពេញឲ្យធាតុផ្សំ នានានៃ "អំពើអមនុស្សធម៌ផ្សេងៗទៀត" ហើយបង្កើតបានជា ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ ហើយ មិនដូចគ្នាទៅនឹងនិយមន័យនៃការមានផ្ទៃពោះដោយបង្ខំរបស់លក្ខន្តិកៈទីក្រុងរ៉ូមនោះទេ ឧក្រិដ្ឋកម្មនេះ វាមិនតម្រូវឲ្យមានសក្ខីកម្មដែលថា ជនរងគ្រោះត្រូវបានឃុំឃាំងដោយខុសច្បាប់ ឬក៏អ្នកប្រព្រឹត្តបទល្មើសមានបំណងជាក់លាក់ធ្វើឲ្យប៉ះពាល់ដល់សមាសភាពជាតិពន្ធុនៃប្រជាជនណាមួយ ឬក៏បានប្រព្រឹត្តនូវការរំលោភដ៏ធ្ងន់ធ្ងរផ្សេងៗទៀតនៃច្បាប់អន្តរជាតិនោះឡើយ។ ចុងបញ្ចប់ សពអ សូមជូនសេចក្តីសន្និដ្ឋានថា ការកំណត់បទចោទប្រកាន់អំពីអង្គហេតុនានានៅក្នុងសំណុំរឿង០០៤ រួមមានការកំណត់បទចោទប្រកាន់អំពីគោលនយោបាយនានាដើម្បីបង្ខំស្ត្រី និងក្មេងស្រីឲ្យមានផ្ទៃពោះ គឺត្រូវបានដាក់យ៉ាងល្អបំផុតនៅត្រង់សេចក្តីបញ្ចប់នៃការស៊ើបសួរប្រឆាំងនឹង អោ អាន និង យឹម ទិត កាលណាអង្គហេតុទាំងឡាយនោះត្រូវបានស៊ើបអង្កេតទាំងស្រុងរួចហើយ។

## II. ច្បាប់ជាធរមាន

៤. យុត្តិសាស្ត្ររបស់ អវតក សម្រេចថា "អំពើអមនុស្សធម៌ផ្សេងៗទៀត" ជាឧក្រិដ្ឋកម្មនានាប្រឆាំងនឹងមនុស្សជាតិ មានធាតុផ្សំតាមផ្លូវច្បាប់ ជាការបន្ថែមទៅនឹងលក្ខខណ្ឌតម្រូវ *គ្របដណ្តប់* នៅក្នុងមាត្រា៥ នៃច្បាប់ អវតក ដូចតទៅ[4]៖

(១) មានអំពើ ឬ ការប្រព្រឹត្ត,

(២) ដែលបណ្តាលឲ្យប៉ះពាល់ដល់រាងកាយយ៉ាងធ្ងន់ធ្ងរ ឬ ព្យសនកម្មផ្លូវចិត្ត ឬបង្កើតឲ្យមានការវាយប្រយុទ្ធយ៉ាងធ្ងន់ធ្ងរទៅលើសេចក្តីថ្លៃថ្នូររបស់មនុស្ស,

(៣) ដែលបានប្រព្រឹត្តទៅដោយគិតទុកជាមុន ដោយមានចេតនាធ្វើឲ្យមានរបួសដល់រាងកាយ ឬ ព្យសនកម្មផ្លូវចិត្ត ឬ ប្រព្រឹត្តនូវការវាយប្រយុទ្ធយ៉ាងធ្ងន់ធ្ងរទៅលើសេចក្តីថ្លៃថ្នូររបស់មនុស្សនៃជនរងគ្រោះ នៅពេលនៃអំពើ ឬ ការប្រព្រឹត្ត, និង

(៤) អំពើ ឬ ការប្រព្រឹត្ត គឺមាន ចរិកលក្ខណៈ និង ទម្ងន់ ស្រដៀងគ្នាទៅនឹងឧក្រិដ្ឋកម្មនានាប្រឆាំងនឹងមនុស្សជាតិដែលបានរៀបរាប់ផ្សេងៗទៀត។

---

4 សូមអាន សំណុំរឿង០០២/០១-**E313** សាលក្រម, ៧ សីហា ២០១៤, កថាខណ្ឌ៤៣៧។

ទម្ងន់នៃ អំពើ ឬ ការប្រព្រឹត្ត គឺត្រូវបានវាយតម្លៃទៅតាមករណីរឿងនីមួយៗ ដោយគិតពីកាលៈទេសៈរបស់បុគ្គលនៃករណីរឿង[5]។

៥. "អំពើអមនុស្សធម៌ផ្សេងៗទៀត" គឺជាបំណែកដែលសល់នៃប្រភេទ ដែលមានបំណងចាប់យកនូវរាល់ការ ប្រព្រឹត្តដែលមានទម្ងន់បែបដូច្នេះ ជាជាងទុកឱ្យមោឃៈចោល ខណៈដែលអ្នកប្រព្រឹត្តបទល្មើស ដែលចូលចិត្តនឹកគិតថានឹងត្រូវសប្បាយជាមួយនឹងនិទណ្ឌភាព[6]។

---

[5] សូមអាន សំណុំរឿង០០២/០១-**E313** សាលក្រម, ៧ សីហា ២០១៤, កថាខណ្ឌ៤៣៨។

[6] *រដ្ឋអាជ្ញា ទល់នឹង Blaškić*, សំណុំរឿងលេខ IT-95-14-T, សាលក្រម, ៣ មីនា ២០០០, កថាខណ្ឌ២៣៧, ដែលបានពិភាក្សាពី "អំពើអមនុស្សធម៌ផ្សេងៗទៀត" និង ដកស្រង់ J. Pictet, *សេចក្តីអត្ថាធិប្បាយអំពីកតិកាសញ្ញាទីក្រុងហ្សឺណែវលើកទី១ ចុះថ្ងៃទី១២ ខែសីហា* ឆ្នាំ១៩៤៩, ១៩៥៤, ទំព័រ៥៤៖ "[...] វាជាការគ្រោះថ្នាក់ជានិច្ចក្នុងការដែលព្យាយាមចូលទៅក្នុងសេចក្តីពិស្តារយ៉ាងខ្លាំង - ជាពិសេសនៅក្នុងផ្នែកនេះ [ការឱ្យនិយមន័យ "ការឃុំគ្រងតាមបែបមនុស្សធម៌" នៅក្នុងមាត្រា៣។ យ៉ាងណាក៏ដោយ ការយកចិត្តទុកដាក់ជាច្រើនត្រូវបានគេធ្វើឡើងនៅក្នុងការបង្កើតជាបញ្ជីមួយនៃរាល់ទម្រង់ផ្សេងៗនៃការធ្វើឱ្យឈឺចាប់ មិនមាននរណាម្នាក់អាចចាប់បាននូវការគិតស្រមៃពីអនាគតអ្នកធ្វើទារុណកម្មនានាដែលប្រាថ្នាចង់បានឱ្យត្រូវទៅតាមសភាវៈគតិសត្វរបស់ខ្លួន, ហើយពិសេសជាងនេះ និងបំពេញនូវបញ្ជីមួយដែលព្យាយាមចង់បាន, វាក្លាយទៅជាកាន់តែតឹងតែង"]។ សូមអានផងដែរ សំណុំរឿង០០១-**E188** សាលក្រម, ២៦ កក្កដា ២០១០, កថាខណ្ឌ៣៦៧៖ "អំពើអមនុស្សធម៌ផ្សេងៗទៀត រួមមានបទល្មើសដែលនៅសេសសល់ផ្សេងៗទៀតដែលមានបំណងចាត់ទុកអំពើនោះថាជាបទល្មើស នៅពេលដែលអំពើនោះបំពេញលក្ខខណ្ឌតម្រូវនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ប៉ុន្តែមិនបានបំពេញលក្ខខណ្ឌតម្រូវនៃបទល្មើសមួយក្នុងចំណោមបទល្មើសជាក់លាក់ផ្សេងៗទៀតឡើយ"។ សំណុំរឿង០០២-**D427/3/15** សាលដីកាលើបណ្តឹងឧទ្ធរណ៍ធ្វើឡើងដោយ នួន ជា និង អៀង ធីរិទ្ធ ប្រឆាំងនឹងដីកាដំណោះស្រាយ, ១៥ កុម្ភៈ ២០១១, កថាខណ្ឌ១៦១៖ "ប្រភេទនៃ "អំពើអមនុស្សធម៌ផ្សេងៗទៀត" ជាឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិត្រូវបានចែងជាក់លាក់ជាបទល្មើសមួយសេសសល់ ដើម្បីបញ្ចៀសនូវភាពចន្លោះប្រហោងនៅក្នុងច្បាប់ ហើយថាពាក្យនេះមិនមានន័យប្រសិនបើមិនយក*គោលការណ៍នៃការបញ្ចូលគ្នាជាក្រុមតែមួយ នូវអ្វីដែលមានភាពស្រដៀងគ្នា (ejusdem generis)* មកអនុវត្ត។ *រដ្ឋអាជ្ញា ទល់នឹង Brima និងគូកន*, សំណុំរឿង SCSL-04-16-A, សាលដីកា, ២២ កុម្ភៈ ២០០៨, កថាខណ្ឌ ១៨៣ និង ១៨៥៖ "ឧក្រិដ្ឋកម្មនៃ "អំពើអមនុស្សធម៌ផ្សេងៗទៀត" គឺមានបំណងជាបទប្បញ្ញត្តិកាកសំណល់ ជាប្រយោជន៍ដាក់ទណ្ឌកម្ម លើអំពើព្រហ្មទណ្ឌដែលមិនបានទទួលស្គាល់ថាជាឧក្រិដ្ឋកម្មនានាដែលប្រឆាំងមនុស្សជាតិ ប៉ុន្តែនៅក្នុងបរិបទ វាមានទម្ងន់ប្រហាក់ប្រហែលគ្នាទៅនឹងឧក្រិដ្ឋកម្មនានាដែលប្រឆាំងនឹងមនុស្សជាតិដែលបានចុះបញ្ជី។ ដូច្នេះ វាត្រូវបានគិតបញ្ចូលទៅតាមចរិតលក្ខណៈ ដោយមានបំណងចៀសវាងដោយមិនត្រឹមត្រូវចំពោះការកម្រិតការអនុវត្តលក្ខន្តិកៈចំពោះឧក្រិដ្ឋកម្មនានាប្រឆាំងនឹងមនុស្សជាតិ ...។ តុលាការត្រូវតែយកចិត្តទុកដាក់មិនត្រូវអនុវត្តតឹងតែងពេកនូវការបកស្រាយការហាមឃាត់ប្រឆាំងនឹង "អំពើអមនុស្សធម៌ផ្សេងៗទៀត" ដែលដូចបានជម្រាបនៅខាងលើ មានបំណងធ្វើជាបទប្បញ្ញត្តិកាកសំណល់"។ *រដ្ឋអាជ្ញា ទល់នឹង Stakić*, សំណុំរឿង IT-97-24-A, សាលដីកា, ២២ មីនា ២០០៦, កថាខណ្ឌ៣១៥ ដោយបានដកស្រង់ *រដ្ឋអាជ្ញា ទល់នឹង Kupreškić និង គូកន*, សំណុំរឿង IT-95-16-T, សាលក្រម, ១៤ មករា ២០០០, កថាខណ្ឌ៥៦៣៖ "ឃ្លា "អំពើអមនុស្សធម៌ផ្សេងៗ ទៀត" ត្រូវបានតាក់តែងឡើងដោយមានបំណងធ្វើជាប្រភេទកាកសំណល់ ព្រោះវាត្រូវបានធ្លាក់ចូលទៅក្នុងប្រភេទនេះ

## III. អំណះអំណាង

### ក. និយមន័យនៃ "ការមានផ្ទៃពោះដោយបង្ខំ" នៅក្នុងលក្ខន្តិកៈទីក្រុងរ៉ូម គឺមិនអាចអនុវត្តបានទេចំពោះ អវតក

៦. ជាការធានានូវគោលការណ៍នីត្យានុកូលភាព ច្បាប់យុត្តិសាស្ត្ររបស់ អវតក បានបញ្ជាក់ថា "យុត្តាធិការ ... លើឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ត្រូវបានកំណត់ដោយនិយមន័យនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដូចដែលមានចែងនៅក្នុងច្បាប់អន្តរជាតិនៅក្នុងអំឡុងពេលនៃ[របបកម្ពុជាប្រជាធិបតេយ្យ]" ហើយមិនដូចចែងនៅក្នុងលក្ខន្តិកៈទីក្រុងរ៉ូមទេ[7]។ លក្ខន្តិកៈទីក្រុងរ៉ូម ត្រូវបានចរចានៅឆ្នាំ១៩៩៨ និងបានផ្តល់ភស្តុតាងរបស់រដ្ឋបន្តិចបន្តួច ឬ គ្មានសោះ អំពីច្បាប់ទំនៀមទម្លាប់អន្តរជាតិនៅក្នុងរយៈកាលនៃយុត្តាធិការពេលវេលារបស់ អវតក (ឆ្នាំ១៩៧៥-១៩៧៩)។ វាពុំមែនមានន័យដើម្បីប្រមូលជាច្បាប់ទំនៀមទម្លាប់អន្តរជាតិ[8] ហើយយុត្តិសាស្ត្រផ្ទាល់ របស់តុលាការព្រហ្មទណ្ឌអន្តរជាតិបញ្ជាក់បញ្ហាដែលថា តើលក្ខន្តិកៈទីក្រុងរ៉ូម អនុលោមតាមច្បាប់ ទំនៀមទម្លាប់អន្តរជាតិ គឺមិនពាក់ព័ន្ធគ្នាទេ សម្រាប់គោលដៅនៃការបកស្រាយរបស់វា[9]។

៧. មាត្រា៧(២)(ច) នៃលក្ខន្តិកៈទីក្រុងរ៉ូមបានផ្តល់និយមន័យឲ្យ "ការមានផ្ទៃពោះដោយបង្ខំ" ថា៖

---

ដោយមិនគប្បីប្រាថ្នាឡើយ ថាត្រូវបានរៀបរាប់ហួសហេតុពេក។ ប្រភេទដែលបានរៀបរាប់ហួសហេតុនេះ គឺគ្រាន់តែបានបង្កើតនូវឱកាសនៃការផ្លាស់ប្តូរអក្សរនៃការហាមឃាត់ ប៉ុណ្ណោះ"។

7 សំណុំរឿង០០២/០១-**E313** សាលក្រម, ៧ សីហា ២០១៤, កថាខណ្ឌ១៩ ដោយបានលើកឡើងពីសំណុំរឿង០០១-**F28** សាលក្រម, ៣ កុម្ភៈ ២០១២, កថាខណ្ឌ ៩៩-១០០។

8 លក្ខន្តិកៈទីក្រុងរ៉ូម តាមវាក្យស័ព្ទផ្ទាល់របស់វា មិនបានអះអាងថាត្រូវបង្ហាញច្បាប់ទំនៀមទម្លាប់ ប៉ុន្តែមានតែច្បាប់កំនត់ជាអនាគតសម្រាប់គោលបំណងនានានៃលក្ខន្តិកៈខ្លួនឯងប៉ុណ្ណោះ។ *រដ្ឋអាជ្ញា ទល់នឹង Orić*, សំណុំរឿង IT-03-68-A, សាលក្រម, មតិផ្ទុយខ្លះ១ និង ដោយឡែក របស់ចៅក្រម Schomburg, ៣ កក្កដា ២០០៨, កថាខណ្ឌ២០។ មាត្រា៧ នៃលក្ខន្តិកៈទីក្រុងរ៉ូម បានថ្លែងយ៉ាងច្បាស់ថា "សម្រាប់គោលដៅនៃលក្ខន្តិកៈ *នេះ* "ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ" មានន័យថា ..." (សង្កត់ន័យបន្ថែមដោយ*អក្សរទ្រេត*), និងមាត្រា១០ ថ្លែងថា "ពុំមានអ្វីនៅក្នុងផ្នែកនេះ [យុត្តិសាស្ត្រ, ភាពអាចទទួលយកបាន និង ច្បាប់ជាធរមាន] ត្រូវបានបកស្រាយដោយការកម្រិត ឬ សេចក្តីលំអៀងតាមបែបណាក៏ដោយដែលអាចមានបាន ឬ ដែលបង្កើតនូវវិធាននានានៃច្បាប់អន្តរជាតិ សម្រាប់គោលបំណងផ្សេងពីលក្ខន្តិកៈនេះ"។

9 សូមអាន *ស្ថានការណ៍នៅក្នុងសាធារណៈរដ្ឋប្រជាធិបតេយ្យកុងហ្គោ នៅក្នុងសំណុំរឿង រដ្ឋអាជ្ញា ទល់នឹង Katanga និង Chui*, សំណុំរឿង ICC-01/04-01/07, សេចក្តីសម្រេចស្តីពីការអះអាងបទចោទ, ៣០ កញ្ញា ២០០៨, កថាខណ្ឌ៥០៨៖ "ប្រភពទីមួយនៃច្បាប់ជាធរមានគឺ លក្ខន្តិកៈ[ទីក្រុងរ៉ូម]។ គោលការណ៍ និង វិធានផ្ទៃក្នុងនៃច្បាប់អន្តរជាតិ បង្កើតបានជាប្រភពទីពីរអនុវត្តបាន តែកាលណាសម្ភារៈលក្ខន្តិកៈខកខានមិនបានចេញនូវដំណោះស្រាយតាមផ្លូវច្បាប់"។

ការឃុំឃាំងដោយខុសច្បាប់នូវស្ត្រីណាម្នាក់ បង្ខំធ្វើឱ្យមានផ្ទៃពោះ ដោយមានចេតនាធ្វើឱ្យប៉ះពាល់ដល់សមាសភាពជាតិពន្ធនៃប្រជាជនណាមួយ ឬ បានប្រព្រឹត្តនូវការរំលោភដ៏ធ្ងន់ធ្ងរផ្សេងៗទៀតនៃច្បាប់អន្តរជាតិ។ និយមន័យនេះ តាមបែបណាក៏ដោយ មិនត្រូវបកស្រាយថា ប៉ះពាល់ដល់ច្បាប់ជាតិទាក់ទងនឹងការមានផ្ទៃពោះ នោះឡើយ [.]។

៨. និយមន័យនេះគឺជាលទ្ធផលនៃការចរចាររវាងគណប្រតិភូ ដែលគោលបំណងនៃការធានាឱ្យមានការស្រុះស្រួលគ្នា "បានអនុញ្ញាតឱ្យរដ្ឋអវិភូត ... បដិសេធទទួលយកពាក្យពេចន៍ដែលគាំទ្រដោយចំនួនភាគច្រើន ដូច្នេះបានបង្ខំឱ្យបទប្បញ្ញត្តិជាច្រើនចុះខ្សោយអានុភាព"[10]។ និយមន័យនេះទទួលរងឥទ្ធិពលខ្លាំងពីព្រឹត្តិការណ៍ប្រវត្តិសាស្ត្រជាក់លាក់ ដែលវាត្រូវបានបង្កើតឡើង។ គណប្រតិភូដែលគាំទ្រនិយមន័យការមានផ្ទៃពោះដោយបង្ខំ ដែលជាចុងក្រោយត្រូវបានអនុម័តនោះ ចង់បាននិយមន័យមួយដែលឆ្លុះបញ្ចាំងវិសាលភាពទាំងមូល នៃឧក្រិដ្ឋកម្មនៃជំរុំនៃការរំលោភសេពសន្ថវៈ ដែលបានបង្កើតឡើងក្នុងអំឡុងពេលសង្គ្រាមនៅ បូស្នៀ និង Herzegovinaដែលជាកន្លែងដែលត្រូវបានចោទថា ស្ត្រី និងក្មេងស្រីត្រូវបានរំលោភសេពសន្ថវៈ និងត្រូវបានរក្សាទុកជាចំណាប់ខ្លាំងរហូតទាល់តែវាហួសពេលក្នុងការបញ្ចប់ការមានផ្ទៃពោះរបស់ពួកគេយ៉ាងមានសុវត្ថិភាពនោះ[11]។

---

10 អត្ថបទរបស់ B. Bedont និង K. Martinez, *ការបញ្ចប់និទណ្ឌភាពឧក្រិដ្ឋកម្មផ្លូវភេទនៅតុលាការព្រហ្មទណ្ឌអន្តរជាតិ (Ending Impunity for Gender Crimes under the International Criminal Court)*, ព្រឹត្តិប័ត្រ The Brown Journal of World Affairs, វ៉ូលូម. VI (1999), លេខ 1, 65-85 ត្រង់ទំព័រ ៦៧។ **<u>ទាក់ទងនឹងបទប្បញ្ញត្តិលក្ខន្តិកៈទីក្រុងរ៉ូមស្តីពីការមានផ្ទៃពោះដោយបង្ខំ</u>**, សូមមើលផងដែរ៖ អត្ថបទរបស់ S. Jessie, *Forced Pregnancy: Codification in the Rome Statute and its Prospect as Implicit Genocide*, ព្រឹត្តិប័ត្ត New Zealand Journal of Public International Law, វ៉ូលូម. 4 (2006), 311-337, ត្រង់ ទំ. 328។ អត្ថបទរបស់ K. Boon, *Rape and Forced Pregnancy under the ICC Statute: Human Dignity, Autonomy, and Consent*, ព្រឹត្តិប័ត្រ Columbia Human Rights Law Review, វ៉ូលូម. 32 (2001), 625-674, ត្រង់ ទំ. 630 និង 637-638។ អត្ថបទរបស់ A. Drake, *Aimed at Protecting Ethnic Groups or Women? A look at Forced Pregnancy Under the Rome Statute*, ព្រឹត្តិប័ត្រ William & Mary Journal of Women and the Law, វ៉ូលូម. 18 (២០១២), លេខ 3, 594-623, ត្រង់ ទំ. 607-608។ អត្ថបទរបស់ J. Joseph, *Gender and International Law: How the International Criminal Court Can Bring Justice to Victims of Sexual Violence*, ព្រឹត្តិប័ត្រ Texas Journal of Women and the Law, វ៉ូលូម. 18 (2008), 61-101, ត្រង់ ទំ. 82-83។ **<u>ទាក់ទងនឹងបទប្បញ្ញត្តិផ្សេងទៀតនៃលក្ខន្តិកៈទីក្រុងរ៉ូម</u>** សូមមើល *ឧ. ៖ រដ្ឋអាជ្ញា ទល់នឹង Orić*, IT-03-68-A, សាលក្រម, យោបល់ដោយឡែក និងយោបល់ជំទាស់ដោយផ្នែករបស់ចៅក្រម Schomburg, ៣ កក្កដា ២០០៨, កថាខណ្ឌ ២០៖ "មាត្រារាងខ្លួននៃលក្ខន្តិកៈរបស់ ICC គឺជាប្រធានបទនៃការចរចារដ៏លំបាក ដែលនាំឱ្យមាន 'ការសម្រុះសម្រួលដ៏ពិបាក'"។

11 អត្ថបទរបស់ C. Steains, *Gender Issues*, នៅក្នុង R. Lee (ed.), *The International Criminal Court: the Making of the Rome Statute, Issues, Negotiators, and Results*, ៦ កញ្ញា ១៩៩, ទំ. 357–390, ត្រង់ ទំ. 366។

នៅពេលដែលគណប្រតិភូមួយបានស្នើនិយមន័យនៃ "ការមានផ្ទៃពោះដោយបង្ខំ" ដែលសំដៅទៅលើតែ*ការធ្វើ* យ៉ាងបង្ខំ (និងមិនមែន*ការបន្តទុក*) ឱ្យស្ត្រី ឬក្មេងស្រីមានផ្ទៃពោះផ្ទុយទៅនឹងឆន្ទៈរបស់នាងនោះ វាត្រូវរិះគន់ដោយឈរលើមូលដ្ឋានដែលថា វាមិនបានរៀបរាប់ឱ្យបានពេញលេញអំពីការទទួលខុសត្រូវរបស់ជនប្រព្រឹត្តនៅក្នុងស្ថានភាពនៅ បូស្នៀ និង Herzegovina[12]។ ជាងនេះទៀត និយមន័យក៏ត្រូវបានរងឥទ្ធិពលដោយការព្រួយបារម្ភទៅនឹងការធ្វើឱ្យមានការបន្ធូរបន្ថយចំពោះអ្នកដែលភ័យខ្លាចចំពោះ ការប្រព្រឹត្តការរំលោភសេពសន្ថវៈក្នុងអាពាហ៍ពិពាហ៍ទៅជាបទល្មើសព្រហ្មទណ្ឌ[13] និងការបដិសេធមិនព្រមទទួលយកសេវារំលូតកូន[14]។

៩. ដោយពិចារណាទៅលើប្រវត្តិនៃការចរចារគ្នានេះ និងអង្គហេតុដែលថាលក្ខន្តិកៈទីក្រុងរ៉ូម មិនមែនជាកត្តាកំណត់នៃច្បាប់ទំនៀមទម្លាប់អន្តរជាតិក្នុងអំឡុងពេលរបបកម្ពុជាប្រជាធិបតេយ្យ មិនមានហេតុផលណាមួយក្នុងការនាំយកជាស្វ័យប្រវត្តិនូវធាតុផ្សំនៃនិយមន័យ ការមានផ្ទៃពោះដោយបង្ខំរបស់លក្ខន្តិកៈទីក្រុងរ៉ូមនោះឡើយ។ ផ្ទុយទៅវិញ សពអ យល់ឃើញថា វិធីសាស្ត្រដ៏ត្រឹមត្រូវនោះគឺត្រូវពិនិត្យលើទង្វើដែលបាននោះដើម្បីកំណត់ថា៖

១. តើវាបំពេញគ្រប់ធាតុផ្សំនៃឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិនៃ 'អំពើអមនុស្សធម៌ផ្សេងៗទៀត' ក្នុងច្បាប់ទំនៀមទម្លាប់អន្តរជាតិចាប់ផ្តើមពីឆ្នាំ ១៩៧៥ ដែរឬទេ និង

២. ថាតើការទទួលខុសត្រូវរបស់ជនប្រព្រឹត្តបទល្មើស និងព្យសនកម្មចំពោះជនរងគ្រោះ ត្រូវបានគ្របដណ្តប់គ្រប់គ្រាន់ដោយនិយមន័យនៃឧក្រិដ្ឋកម្មផ្សេងៗទៀតដែរឬយ៉ាងណា។

---

[12] អត្ថបទរបស់ C. Steains, *Gender Issues*, នៅក្នុង R. Lee (ed.), *The International Criminal Court: the Making of the Rome Statute, Issues, Negotiators, and Results*, ៦ កញ្ញា ១៩៩៩, 357–390, ត្រង់ទំព័រ. 366។

[13] អត្ថបទរបស់ S. Jessie, *Forced Pregnancy: Codification in the Rome Statute and its Prospect as Implicit Genocide*, ព្រឹត្តិប័ត្រ New Zealand Journal of Public International Law, វ៉ុល្លម. 4 (2006), 311-337, ត្រង់ទំព័រ. 325 និង 329។

[14] អត្ថបទរបស់ S. Jessie, *Forced Pregnancy: Codification in the Rome Statute and its Prospect as Implicit Genocide*, ព្រឹត្តិប័ត្រ New Zealand Journal of Public International Law, វ៉ុល្លម. 4 (2006), 311-337, ត្រង់ទំព័រ. 322-325 និង 328។ អត្ថបទរបស់ B. Bedont និង K. Martinez, *Ending Impunity for Gender Crimes under the International Criminal Court*, ព្រឹត្តិប័ត្រ The Brown Journal of World Affairs, វ៉ុល្លម. VI (1999), លេខ 1, 65-85 ត្រង់ទំព័រ ៦៨ និង ៧៤។ អត្ថបទរបស់ A. Drake, *Aimed at Protecting Ethnic Groups or Women? A look at Forced Pregnancy Under the Rome Statute*, ព្រឹត្តិប័ត្រ William & Mary Journal of Women and the Law, វ៉ុល្លម. 18 (២០១២), លេខ 3, 594-623, ត្រង់ទំព័រ 607-608។ អត្ថបទរបស់ J. Joseph, *Gender and International Law: How the International Criminal Court Can Bring Justice to Victims of Sexual Violence*, ព្រឹត្តិប័ត្រ Texas Journal of Women and the Law, វ៉ុល្លម. 18 (2008), 61-101, ត្រង់ទំព័រ. 82-83។

## ខ. ការធ្វើឱ្យមានផ្ទៃពោះដោយបង្ខំស្ថិតនៅក្នុងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ នៃ 'អំពើអមនុស្សធម៌ផ្សេងៗទៀត'

១០. ឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិត្រូវបានពិពណ៌នាថាជាឧក្រិដ្ឋកម្មដែល "ធ្វើឱ្យរន្ធត់តក់ស្លុតដល់សតិសម្បជញ្ញៈរបស់មនុស្សជាតិ"[15]។ ស្ថានភាពនេះរួមបញ្ចូលទាំងឧក្រិដ្ឋកម្មនៃ "អំពើអមនុស្សធម៌ផ្សេងៗទៀត" ដែលមានដើមកំណើតចេញមកពី "សិទ្ធិជាមូលដ្ឋានមួយក្រុមរបស់មនុស្សជាតិដែលអាស្រ័យលើកាលៈទេសៈជាក់លាក់នោះ ការរំលោភបំពានលើសិទ្ធិទាំងនេះអាចបង្កើតបានជាឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ"[16]។ សពអ យល់ឃើញថាស្ថានភាពនេះរួមបញ្ចូលជាចាំបាច់នូវតម្លៃនៃសិទ្ធិដាច់ខាតរបស់មនុស្ស ដូចជា សេចក្ដីថ្លៃថ្នូររបស់មនុស្ស ស្វ័យភាព សមភាព និងជម្រើសក្នុងការបន្តពូជ[17]។

---

15 L. Sadat, ប្រមូលចងក្រង "ច្បាប់ស្ដីពី មនុស្សជាតិ" និង "ឥទ្ធិពលមនសិការសាធារណៈ"៖ ចំពោះសន្ធិសញ្ញាសាកលថ្មីស្ដីពី ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ, ឱ្យទៅជាច្បាប់ក្នុងអត្ថបទរបស់ M. Bergsmo និង Song T. eds., *On the Proposed Crimes Against Humanity Convention*, ១២ កញ្ញា ២០១៤,១៧-៤៦ ទំ. ១៨។ ទស្សនៈនេះត្រូវបានបញ្ជាក់នៅក្នុងបុព្វកថានៃសេចក្ដីប្រកាសជាសកលស្ដីពីសិទ្ធិមនុស្សៈ ១០ ធ្នូ ១៩៤៨ ("UDHR"): "ដោយហេតុត ការមិនគោរព និងការរំលោភសិទ្ធិមនុស្សបានបណ្ដាលឲ្យមានអំពើព្រៃផ្សៃ ដែលបានធ្វើប្រមាថយ៉ាងខ្លាំងដល់មនសិការរបស់មនុស្សជាតិ ..."។

16 *រដ្ឋអាជ្ញា ទល់នឹង Kupreškić និងគូកន.*, IT-95-16-T, សាលក្រម, ១៤ មករា ២០០០, កថាខណ្ឌ ៥៦៦។

17 អត្ថបទរបស់ S. Jessie, *Forced Pregnancy: Codification in the Rome Statute and its Prospect as Implicit Genocide*, ព្រឹត្តិប័ត្រ New Zealand Journal of Public International Law, វ៉ុល្លម. 4 (2006), 311-337, ត្រង់ទំព័រ. 317: "ការមានផ្ទៃពោះដោយបង្ខំ ... តម្លៃបង្កប់នៃការការពារស្វ័យភាព សមភាព និងជម្រើសនៃការបន្តពូជ គឺជាសិទ្ធិមនុស្សជាមូលដ្ឋានយូរអង្វែង"។ អត្ថបទរបស់ K. Boon, *Rape and Forced Pregnancy Under the ICC Statute: Human Dignity, Autonomy, and Consent*, ព្រឹត្តិប័ត្រ Columbia Human Rights Law Review, វ៉ុល្លម. 32 (2001), 625-674, ត្រង់ទំព័រ. 631: "ឧក្រិដ្ឋកម្មផ្លូវភេទ ... ផ្អែកតាមគោលការណ៍ទូលាយនៃសេចក្ដីថ្លៃថ្នូររបស់មនុស្ស ស្វ័យភាព និងការយល់ព្រម"។ មាត្រា ១៦ នៃសេចក្ដីប្រកាស Tehran, កិច្ចចុងក្រោយ នៃសន្និសីទអន្តរជាតិស្ដីពីសិទ្ធិមនុស្សឆ្នាំ ១៩៦៨៖ "សិទ្ធិមនុស្សជាមូលដ្ឋានដើម្បីសម្រេចដោយសេរី និងដោយការទទួលខុសត្រូវចំពោះចំនួន និងរយៈពេលមានកូនរបស់ខ្លួន"។ *រដ្ឋអាជ្ញា ទល់នឹង Furundžija*, IT-95-17/1-T, សាលក្រម, ១០ ធ្នូ ១៩៩៨, កថាខណ្ឌ 183: "សារៈសំខាន់ទាំងមូលនៃច្បាប់មនុស្សធម៌អន្តរជាតិ ក៏ដូចជាសិទ្ធិមនុស្សផងដែរ ស្ថិតនៅក្នុងការការពារសេចក្ដីថ្លៃថ្នូររបស់មនុស្សគ្រប់រូប ... គោលការណ៍នេះមានគោលបំណងការពារមនុស្សជាតិពីយាយីលើសេចក្ដីថ្លៃថ្នូររបស់ពួកគេ ថាតើការយាយីនេះត្រូវបានធ្វើឡើងដោយការវាយប្រហាខុសច្បាប់លើរាងកាយ ឬដោយការធ្វើឲ្យអាមាស និងការបន្ថោកបន្ទាបដល់កិត្តិយស សេចក្ដីគោរពខ្លួនឯង ឬសុខុមាលភាពផ្លូវចិត្តរបស់មនុស្សឡើយ"។ **សូមមើលផងដែរ៖** មាត្រា៧ និង ១០ នៃកិត្តិការសញ្ញាអន្តរជាតិស្ដីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ, ១៦ ធ្នូ ១៩៦៦៖ "មាត្រា៧៖ គ្មានជនណាម្នាក់ត្រូវរងទារុណកម្ម ឬការប្រព្រឹត្តិ ឬទណ្ឌកម្ម ដែលឃោរឃៅ អមនុស្សធម៌ ឬធ្វើឲ្យថោកទាបឡើយ។ ... មាត្រា ១០៖ ជនណាដែលត្រូវបានដកហូតសេរីភាព ត្រូវទទួលបានការប្រព្រឹត្តមកលើខ្លួនតាមលក្ខណៈមនុស្សធម៌ និងការគោរពចំពោះសេចក្ដី

ថ្លៃថ្នូរពីកំណើតរបស់មនុស្ស"។ មាត្រា ១, ៣ និង ៥ នៃ UDHR: "មាត្រា១៖ មនុស្សទាំងអស់កើតមកមានសេរីភាព និងសមភាពក្នុងផ្នែកសេចក្តីថ្លៃថ្នូរនិងសិទ្ធិ។ ... មាត្រា៣៖ បុគ្គលម្នាក់ៗមានសិទ្ធិរស់រានមានជីវិត សេរីភាព និងសន្តិសុខផ្ទាល់ខ្លួន។ ... មាត្រា៥៖ គ្មានជនណាម្នាក់ ត្រូវទទួលទារុណកម្ម ឬទណ្ឌកម្ម ឬប្រព្រឹត្តិកម្មកាចសាហាវ ឥតមនុស្សធម៌ ឬថោកទាបបានឡើយ។"។ មាត្រា៥ និង មាត្រា៨ នៃអនុសញ្ញាអឺរ៉ុបស្តីពីការការពារសិទ្ធិមនុស្ស និងសេរីភាពជាមូលដ្ឋាន, ៤ វិច្ឆិកា ១៩៥០៖ "មាត្រា ៥៖ សិទ្ធិមានសេរីភាព និងសន្តិសុខ ... មាត្រា៨៖ សិទ្ធិទទួលបានការគោរពចំពោះជីវិតឯកជន និងជីវិតគ្រួសារ"។ មាត្រា ៥ និង ៧ នៃអនុសញ្ញាអន្តរអាមេរិកកាំងស្តីពីសិទ្ធមនុស្ស, ២២ វិច្ឆិ ១៩៦៩៖ "មាត្រា៥៖ សិទ្ធិទទួលបានការប្រព្រឹត្តប្រកបដោយមនុស្សធម៌ ១. មនុស្សគ្រប់រូបមានសិទ្ធិទទួលបានការគោរពខាងផ្នែករូបរាងកាយ ផ្លូវចិត្ត និងសេចក្តីថ្លៃថ្នូរ។ ២. គ្មានជនណាម្នាក់ត្រូវទទួលរងទារុណកម្ម ឬអំពើឃោឃៅ អមនុស្សធម៌ ឬការដាក់ទណ្ឌកម្ម ឬការប្រព្រឹត្តបន្ទាបបន្ថោកនោះទេ។ មនុស្សទាំងអស់ដែលត្រូវបានដកហូតសេរីភាពរបស់ខ្លួន ត្រូវទទួលបានការប្រព្រឹត្ត ដោយការគោរពចំពោះសេចក្តីថ្លៃថ្នូរជាមនុស្សជាតិ ... មាត្រា៧៖ សិទ្ធិចំពោះសេរីភាពផ្ទាល់ខ្លួន ១.មនុស្សគ្រប់រូបមានសិទ្ធិទទួលបានសេរីភាព និងសន្តិសុខផ្ទាល់ខ្លួន"។ **<u>ទាក់ទងនឹងការធ្វើឲ្យមានផ្ទៃពោះដោយបង្ខំ ជាការរំលោភលើសិទ្ធិមនុស្ស និងសិទ្ធិមនុស្សធម៌ជាមូលដ្ឋាន៖</u>** សេចក្តីប្រកាស និងកម្មវិធីសកម្មភាពទីក្រុង វីយែន, ២៥ មិថុនា ១៩៩៣, កថាខណ្ឌ I.18 និង II.B.3.38៖ "18. សិទ្ធិមនុស្សរបស់ស្ត្រី និងក្មេងស្រីគឺជាផ្នែក មិនពាចដកហូតបាន ជាផ្នែករួមនិងមិនអាចបំបែកបាន នៃសិទ្ធិមនុស្សជាសកល ... ការលុបបំបាត់រាល់ទម្រង់នៃការរើសអើងដោយឈរលើមូលហេតុ ភេទ គឺជាគោលបំណងអាទិភាពនៃសហគមន៍អន្តរជាតិ ... 38. ជាពិសេស សន្និសីទពិភពលោកស្តីពីសិទ្ធិមនុស្ស សង្កត់ធ្ងន់លើសារៈសំខាន់នៃការធ្វើការផ្តោះទៅរកការលុបបំបាត់អំពើហិង្សារប្រឆាំងនឹងស្ត្រី ក្នុងជីវិតសាធារណៈ និងជីវិតឯកជន ការលុបបំបាត់រាល់ទម្រង់នៃការកេងប្រវ័ញ្ច ... ផ្លូវភេទ ... ការលុបបំបាត់ភាពអយុត្តិធម៌យេនឌ័រក្នុងការគ្រប់គ្រងយុត្តិធម៌ ... ការរំលភពសិទ្ធិមនុស្សរបស់ស្ត្រីក្នុងស្ថានភាពជម្លោះប្រដាប់អាវុធគឺជាការរំលោភលើគោលការណ៍ជាមូលដ្ឋាននៃសិទ្ធិមនុស្សអន្តរជាតិ និងច្បាប់មនុស្សធម៌។ រាល់ការរំលោភទាំងអស់ប្រភេទបែបនេះ រួមបញ្ចូលទាំង ជាពិសេសនោះ ... ការមានផ្ទៃពោះដោយបង្ខំ ទាមទារឲ្យមានអនុភាពជាក់លាក់"។ សេចក្តីប្រកាសទីក្រុងប៉េកាំង និងផែនការសកម្មភាព, ១៥ កញ្ញា ១៩៩៥, កថាខណ្ឌ ១១៤, ១៣២ និង ១៣៥៖ "114. អំពើផ្សេងៗទៀតនៃអំពើហិង្សារប្រឆាំងនឹងស្ត្រី រួមបញ្ចូលទាំងការរំលោភសិទ្ធិមនុស្សរបស់ស្ត្រី ក្នុងស្ថានភាពជម្លោះប្រដាប់អាវុធ ជាពិសេស ... ការមានផ្ទៃពោះដោយបង្ខំ ... 132 ... សេចក្តីប្រកាសទីក្រុង វីយែន និងកម្មវិធីសកម្មភាព ... ថ្លែងថា '...ការមានផ្ទៃពោះដោយបង្ខំទាមទារជាពិសេស ការឆ្លើយតបដ៏មានប្រសិទ្ធភាព' ... 135. ខណៈដែលសហគមន៍ទាំងមូលទទួលរងគ្រោះផលវិបាកនៃជម្លោះប្រដាប់អាវុធ និងភេរវកម្មនោះ ស្ត្រី និងក្មេងស្រីត្រូវបានប៉ះពាល់ជាពិសេសដោយសារតែឋានៈរបស់ពួកគេនៅក្នុងសង្គម និងភេទរបស់ពួកគេ ... ផលប៉ះពាល់នៃអំពើហិង្សារប្រឆាំងនឹងស្ត្រី និងការរំលោភសិទ្ធិមនុស្សរបស់ស្ត្រី ក្នុងស្ថានភាពបែបនោះ ត្រូវបានឆ្លងកាត់ដោយស្ត្រីគ្រប់អាយុកាលទាំងអស់ ... ដែលជាជនរងគ្រោះនៃអំពើនានានៃ ... ការមានផ្ទៃពោះដោយបង្ខំក្នុងស្ថានភាពជម្លោះប្រដាប់អាវុធ ..."។ សេចក្តីសម្រេចចិត្តរបស់គណៈកម្មការ អសប ស្តីពីសិទ្ធិមនុស្ស (អាចរកបាននៅ: https://www1.umn.edu/humanrts/UN/Resolutions98.html (ចូលមើល ១៦ មីនា ២០១៦))៖ Res. 1998/76, ២២ មេសា ១៩៩៨, កថាខណ្ឌ ១៣(ក)៖ "អំពាវនាវដល់រដ្ឋទាំងអស់ឲ្យចាត់គ្រប់វិធានការណ៍ដែលត្រូវការ ... ពីរាល់សកម្មភាពទាំងអស់នៃអំពើហិង្សារដោយផ្អែកលើភេទ រួមបញ្ចូលទាំង ... ការរំលោភដោយបង្ខំ និងដើម្បីពង្រឹងយន្តការស៊ើបអង្កេតនិងផ្តន្ទាទោសជនប្រព្រឹត្តបទល្មើស" ដែលរំលឹកឡើងវិញនូវ Res. 1997/78, 1997, 13(a); Res. 1998/52, ១៧ មេសា ១៩៩៨, កថាខណ្ឌ ៤៖ "ផ្តោលទោសផងដែរនូវរាល់ការរំលោភបំពានទាំងអស់នៃសិទ្ធិមនុស្សរបស់ស្ត្រី ក្នុងស្ថានភាពជម្លោះប្រដាប់អាវុធ ទទួលស្គាល់ពួកវាថាជាការរំលោភលើសិទ្ធមនុស្សអន្តរជាតិ និងច្បាប់មនុស្សធម៌

១១. ការធ្វើឲ្យស្ត្រី ឬក្មេងស្រីមានផ្ទៃពោះប្រឆាំងនឹងឆន្ទៈរបស់នាងនឹង ឬតាមកាលៈទេសៈបង្ខំនានា ពិតជាដល់កម្រិតនៃ 'អំពើអមនុស្សធម៌ផ្សេងៗទៀត'។ ទង្វើបែបនេះពិតជាបណ្តាលឲ្យមានព្យសនកម្មផ្លូវចិត្តធ្ងន់ធ្ងរ ការខូចខាតដល់សេចក្តីថ្លៃថ្នូររបស់មនុស្សជាស្ត្រី ឬក្មេងស្រីនោះ និងអាចមានផលវិបាកដល់ផ្នែកសុខភាព ផ្លូវនៃជីវិត និងផ្នែកសេដ្ឋកិច្ចផងដែរ។ ផលវិបាកនានានឹងប៉ះពាល់ដល់ជីវិតដែលនៅសល់ទាំងស្រុងរបស់នាង ហើយដូច្នេះ ការធ្វើឲ្យមានផ្ទៃពោះដោយបង្ខំមានធាតុផ្សំព្យសនកម្មចំពោះជនរងគ្រោះ ដែលជាចាំបាច់មិនត្រូវបានបង្ហាញនៅក្នុងឧក្រិដ្ឋកម្មរំលោភសេពសន្ថវៈ ឬអាពាហ៍ពិពាហ៍ដោយបង្ខំនោះឡើយ[18]។ ជាងនេះទៀត ការធ្វើឲ្យមានផ្ទៃពោះដោយបង្ខំប្រហែលជាអាចកើតមាននៅក្រៅបរិបទនសការអាពាហ៍ពិពាហ៍ដោយបង្ខំ ឬការរំលោភសេពសន្ថវៈ គេអាចប្រមើលដឹងបានថាស្ត្រី ឬក្មេងស្រីដែលបានរៀបការដោយស្ម័គ្រចិត្ត ឬនឹងស្ម័គ្រចិត្តរៀបការនោះ មិនចង់មានផ្ទៃពោះនៅពេលនោះទេ ឬក៏ថាស្ត្រី ឬក្មេងស្រីយល់ព្រមរួមសង្វាស ប៉ុន្តែស្ថិតក្នុងលក្ខខណ្ឌដែលមិននាំឲ្យរូបនាងមានផ្ទៃពោះ។ ការប៉ុនប៉ងណាមួយដើម្បីបង្ខំស្ត្រី ឬក្មេងស្រីក្នុងកាលៈទេសៈទាំងនេះមានផ្ទៃពោះ នាំឲ្យមានផលវិបាកធ្ងន់ធ្ងរដែលទង្វើនេះមានភាពច្បាស់លាស់ទាំងលក្ខណៈនិងស្ថានទម្ងន់ស្រដៀងគ្នាទៅនឹងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិផ្សេងៗទៀត ដែលមានចែងនៅក្នុងមាត្រា ៥ នៃលក្ខន្តិកៈ អវតក ហើយហេតុដូច្នេះពិតជាបំពេញបានគ្រប់លក្ខខណ្ឌនៃចំណុចចាប់ផ្តើមសម្រាប់ 'អំពើអមនុស្សធម៌ផ្សេងៗទៀត'។

## ឥ. ការទទួលខុសត្រូវ និងព្យសនកម្មសម្រាប់ការធ្វើឲ្យមានផ្ទៃពោះដោយបង្ខំ ខុសគ្នាពីអាពាហ៍ពិពាហ៍ដោយបង្ខំ និងការរំលោភសេពសន្ថវៈ ហើយភាពធ្ងន់ធ្ងរនោះបង្កើតបានជាឧក្រិដ្ឋកម្មមួយដាច់ដោយឡែក ជា 'អំពើអមនុស្សធម៌ផ្សេងៗទៀត

១២. ក្នុងរយៈកាលរបបកម្ពុជាប្រជាធិបតេយ្យ វាអាចកើតមានចំពោះគូស្រករដែលរៀបការដោយបង្ខំទាំងពីរភេទជាជនរងគ្រោះនៃអំពើរំលោភសេពសន្ថវៈ ដោយការបង្ខំឲ្យរួមសង្វាស[19] ប៉ុន្តែ ការធ្វើ

និងអំពាវនាវឲ្យមានការឆ្លើយតបប្រកបដោយប្រសិទ្ធភាពចំពោះការរំលោភបែបនេះ រួមបញ្ចូលទាំង ជាពិសេសនោះ … ការមានផ្ទៃពោះដោយបង្ខំ" ដែលរំលឹកឡើងវិញនៅក្នុង Res. 1997/44, ១១ មេសា ១៩៩៧, កថាខណ្ឌ៥។

18 សូមមើល កថាខណ្ឌ១២ នៃសារណានេះ។

19 សូមមើល *ឧ.*, **D219/217** កំណត់ហេតុនៃការស្តាប់ចម្លើយអ្នកដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ឆេន ហាម, ១១ មីនា ២០១៥, ត្រង់ A180-183: "ខ្ញុំចាំបាច់ត្រូវតែរួមភេទទៅតាមបញ្ជា។ តាមពិតគឺមិនមែនទៅតាមបញ្ជាទេ គឺទៅតាមកាលៈទេសៈ។ យើងមិនអាចជឿទុកចិត្តបានឡើយសម្បីតែនារីដែលជាប្រពន្ធរបស់យើង។ គាត់អាចរាយការណ៍ប្រាប់គេថាខ្ញុំមិនព្រមរួមភេទជាមួយគាត់ ហើយគាត់ក៏ខ្លាចខ្ញុំរាយការណ៍ប្រាប់ពួកគេថាគាត់រឹងរូសមិនព្រមរួមភេទជាមួយខ្ញុំ ដោយសារតែកាលៈទេសៈនេះហើយទើបយើងធ្វើការរួមភេទ។ … នៅក្នុងរបបនេះយើងមិនមានជម្រើសអ្វីឡើយក្រៅពីធ្វើទៅតាមនៅពេលដែលយើងក្លាយទៅជាប្តីប្រពន្ធ … គេអាចយកយើងទៅសម្លាប់ឬព្រមាន ដោយមេបក្សជាន់ខ្ពស់

ឱ្យមានផ្ទៃពោះដោយបង្ខំបានប៉ះពាល់ទាំងស្រុងទៅលើតែស្ត្រី និងក្មេងស្រី និងនាំឱ្យមានព្យសនកម្ម ដាច់ដោយឡែក។ ដូចបានកត់សម្គាល់ដោយអ្នកសិក្សាស្រាវជ្រាវនានា ការធ្វើឱ្យមានផ្ទៃពោះដោយបង្ខំមានលក្ខណៈអាក្រក់ធ្ងន់ធ្ងរជាងផលប៉ះពាល់នៃការរំលោភសេពសន្ថវៈទៅទៀត ដោយការធ្វើការឈ្លានពានលើរូបរាងកាយរបស់ស្ត្រី ឬក្មេងស្រី "ដែលងាយមើលឃើញ និងច្បាស់លាស់ ធ្វើឱ្យជនរងគ្រោះមិនអាចការពារខ្លួនឯងបាន ... តាមរយៈការនៅស្ងាត់ស្ងៀម ឬការបដិសេធ និងបានបង្ហាញជាសញ្ញាឱ្យគេមើលឃើញជនរងគ្រោះនូវស្លាកស្នាមនៃការរំលោភសេពសន្ថវៈនោះ"[20]។ ជនរងគ្រោះនៃការធ្វើឱ្យមានផ្ទៃពោះដោយបង្ខំមើលឃើញរូបរាងកាយរបស់ខ្លួនប្រែប្រួល ជាលទ្ធផលនៃរបួសផ្លូវចិត្តដែលពួកគេទទួលរង[21] ជាញឹកញាប់ត្រូវបង្កើតកូន និងថែរក្សាកូនដែលខ្លួនមិនចង់បាននោះ ត្រូវនឹកឃើញជាប្រចាំថាកូននោះគឺជាលទ្ធផលនៃការរំលោភបំពានលើរាងកាយ និងភាពជនរងគ្រោះ ហើយប្រហែលជាត្រូវស៊ូទ្រាំនឹងស្លាកស្នាមទុរយសសង្គមជាមួយនឹងកូនរបស់ខ្លួន[22]។ ជាងនេះទៀត "ការមានផ្ទៃពោះដែលមិនចង់បាន និងមិនមានគម្រោងទុកមុន" មានផលវិបាកបន្ថែមនិងយូរអង្វែងលើភាពជាម្តាយ ការទទួលខុសត្រូវផ្នែកហិរញ្ញវត្ថុ និងការលំបាក

---

ប្រសិនបើយើងបដិសេធ គឺគេនឹងចាត់ទុកយើងថាជាខ្មាំង ហើយប្រសិនបើគេបញ្ជូនយើងទៅមន្ទីរសន្តិសុខ យើងនឹងមិនអាចមានឱកាសត្រឡប់មកវិញឡើយ"។

20 អត្ថបទរបស់ A. Drake, *Aimed at Protecting Ethnic Groups or Women? A look at Forced Pregnancy Under the Rome Statute*, ព្រឹត្តិប័ត្រ William & Mary Journal of Women and the Law, វ៉ុល្លូម. 18 (២០១២), លេខ 3, 594-623, ត្រង់ទំព័រ. 620 យោង អត្ថបទរបស់ R. Carpenter, *Forced Maternity, Children's Rights and the Genocide Convention: A Theoretical Analysis*, ព្រឹត្តិប័ត្រ Journal of Genocide Research, វ៉ុល្លូម. 2 (2000), លេខ 2, 213-244 ត្រង់ទំព័រ. 223. មើលផងដែរ, អត្ថបទរបស់ S. Jessie, *Forced Pregnancy: Codification in the Rome Statute and its Prospect as Implicit Genocide*, ព្រឹត្តិប័ត្រ New Zealand Journal of Public International Law, វ៉ុល្លូម. 4 (2006), 311-337, ត្រង់ទំព័រ. 329-330។

21 អត្ថបទរបស់ A. Drake, *Aimed at Protecting Ethnic Groups or Women? A look at Forced Pregnancy Under the Rome Statute*, ព្រឹត្តិប័ត្រ William & Mary Journal of Women and the Law, វ៉ុល្លូម. 18 (២០១២), លេខ 3, 594-623, ត្រង់ទំព័រ. 620។

22 អត្ថបទរបស់ A. Drake, *Aimed at Protecting Ethnic Groups or Women? A look at Forced Pregnancy Under the Rome Statute*, ព្រឹត្តិប័ត្រ William & Mary Journal of Women and the Law, វ៉ុល្លូម. 18 (២០១២), លេខ ៣, 594-623, ត្រង់ទំព័រ. 620។ មើលផងដែរ, អត្ថបទរបស់ S. Jessie, *Forced Pregnancy: Codification in the Rome Statute and its Prospect as Implicit Genocide*, ព្រឹត្តិប័ត្រ New Zealand Journal of Public International Law, វ៉ុល្លូម. 4 (2006), 311-337, ត្រង់ទំព័រ. 329-330។

ផ្នែកសុខភាពដែលអាចកើតមាននាពេលខាងមុខ[23]។ របាយការណ៍ថ្មីៗអំពីស្ត្រី Yazadi ដែលត្រូវបានរក្សាទុកជាទាសករផ្លូវភេទដោយអ្នកប្រយុទ្ធ ISIS បង្ហាញឱ្យឃើញពីវិធីដែលជនរងគ្រោះជាញឹកញាប់មើលឃើញព្យសនកម្មនៃការធ្វើឱ្យមានផ្ទៃពោះដោយបង្ខំថាមានលក្ខណៈខុសពី និង ប្រហែលជាមានសភាពធ្ងន់ធ្ងរជាងព្យសនកម្មនៃការរំលោភសេពសន្ថវៈទៅទៀត[24]។ របាយការណ៍បានសរសេរថា ជនរងគ្រោះដែលត្រូវបានសម្ភាសមានអារម្មណ៍ធូរស្រាលដោយសារអ្នករំលោភទាំងនោះទទួចប្រើប្រដាប់ការពារកំណើត។ ស្ត្រី Yazidi ម្នាក់និយាយថា "លើសពីអ្វីៗទាំងអស់ ... ត្រូវបានធ្វើទុក្ខបុកម្នេញដោយអារម្មណ៍ដែលថារូបនាងអាចមានផ្ទៃពោះកូនរបស់ជនដែលរំលោភនាង"។

## ឃ. សំនួរស៊ើបអង្កេតដែលត្រូវសួរ

១៣. ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមរបស់ សពអ ពាក់ព័ន្ធនឹងអាពាហ៍ពិពាហ៍ដោយបង្ខំ និង អំពើហិង្សាដោយមានមូលដ្ឋាននៅលើយ៉េនឌ័រ ("ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែម")[25] ប្តឹង កសចស ដោយមានអង្គហេតុពាក់ព័ន្ធនឹងអាពាហ៍ពិពាហ៍ដោយបង្ខំ និង ការរួមដំណេក។ ជាលទ្ធផល ការស៊ើបសួរចូលទៅក្នុងអង្គហេតុទាំងនោះ ត្រូវមានពាក់ព័ន្ធនឹងសំនួរអំពីផលវិបាកនៃអំពើបែបដូច្នោះ គឺ៖

(១) តើស្ត្រី និង ក្មេងស្រី ដែលបានបង្ខំឱ្យរៀបអាពាហ៍ពិពាហ៍ ដែលបានក្លាយទៅជាមានផ្ទៃពោះនៅអំឡុងពេលកម្ពុជាប្រជាធិបតេយ្យ ត្រូវបានធ្វើឱ្យមានផ្ទៃពោះដោយប្រឆាំងនឹងឆន្ទៈរបស់ពួកគាត់ ឬ ស្ថិតនៅក្រោមកាលៈទេសៈបង្ខិតបង្ខំ[26],

---

[23] អត្ថបទរបស់ K. Boon, *Rape and Forced Pregnancy Under the ICC Statute: Human Dignity, Autonomy, and Consent*, ព្រឹត្តិប័ត្រ Columbia Human Rights Law Review, វ៉ុល្លូម 32 (2001), 625-674, ត្រង់ទំព័រ. 658។

[24] អត្ថបទរបស់ R. Callimachi, *To Maintain Supply of Sex Slaves, ISIS Pushes Birth Control*, សារពត៌មាន The New York Times, ១២ មីនា ២០១៦ (អាចរកបាននៅ http://www.nytimes.com/2016/03/13/world/middleeast/to-maintain-supply-of-sex-slaves-isis-pushes-birth-control.html?_r=0 (ចូលមើលថ្ងៃទី ១៦ មីនា ២០១៦))។

[25] **D191** ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញាអន្តរជាតិទាក់ទងនឹងអាពាហ៍ពិពាហ៍ដោយបង្ខំ ឬអំពើហិង្សាយេនឌ័រ, ២៤ មេសា ២០១៤។

[26] តាមការសិក្សានានាដែលបានធ្វើឡើងដោយអ្នកស្រាវជ្រាវជាន់ខ្ពស់ និងអង្គការមិនមែនរដ្ឋាភិបាល ស្តីពីអាពាហ៍ពិពាហ៍ដោយបង្ខំក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩) បង្ហាញឱ្យឃើញថា ការបង្ខំឱ្យរួមសង្វាសដើម្បីបង្គ្រប់កិច្ចអាពាហ៍ពិពាហ៍ដែលជាលទ្ធផលធ្វើឱ្យស្ត្រីមានគត៌ គឺជាបញ្ហាដែលមានលក្ខណៈរីករាលដាល ដែលបានកើតមានជាទូទៅ និងមានលក្ខណៈកាន់តែអាក្រក់ទៅ ចាប់ពីឆ្នាំ១៩៧៧ មក។ ការសិក្សាទាំងនេះរួមមាន៖ **1. P. LeVine**, *សេចក្តីស្នេហា និងភាពព្រឺព្រួចនៅកម្ពុជា: ការរៀបការ ការចាប់កំណើត និងគ្រោះថ្នាក់នៃការប្រព្រឹត្តពិធីសាសនាផ្សេងៗ*

*នៅក្រោមរបបខ្មែរក្រហម*, ២០១០- (*Love and Dread in Cambodia: Weddings, Births, and Ritual Harm under the Khmer Rouge*, 2010) ចាប់ពីឆ្នាំ១៩៩៧ ដល់២០០៥ (ទំព័រ៧), ការសិក្សានេះបានសម្ភាសន៍ជាផ្លូវការជាច្រើនលើកច្រើនសារជាមួយអ្នកឆ្លើយនឹងសំណួរចំនួន១៩២នាក់ និងមានការពាក់ព័ន្ធនឹងការធ្វើអន្តរសកម្មភាពក្រៅផ្លូវការលើសពី១០០០ដង (ទំព័រ២០, កំណត់សំគាល់ជើងទំព័រ៤) ជាមួយបុគ្គលនានាក្នុងតំបន់ចំនួន១៨កន្លែង នៅទូទាំងប្រទេសកម្ពុជានៅចន្លោះឆ្នាំ១៩៩៧ និង២០០៥ (ទំព័រ៧)។ អ្នកឆ្លើយនឹងសំណួរទាំង១៩២នាក់ គឺសុទ្ធតែជាជនរងគ្រោះនៃអាពាហ៍ពិពាហ៍ដោយបង្ខំនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (ទំព័រ២០, កំណត់សំគាល់ជើងទំព័រ៤) ហើយភាគច្រើនបានរាយការណ៍ថាការរៀបការរបស់ពួកគាត់ត្រូវបានធ្វើឡើងក្នុងក្រុមធំដែលមានចំនួនរហូតដល់៣០០នាក់ (ទំព័រ១៩២)។ ក្នុងចំណោមអ្នកឆ្លើយនឹងសំណួរទាំង១៩២នាក់ ៤០% ត្រូវបាន "បង្គាប់" ឱ្យរួមភេទ (ជាបឋមនៅចន្លោះឆ្នាំ១៩៧៨-១៩៨០) ហើយក្នុងចំណោមស្ត្រីចំនួន១០៤នាក់ដែលស្ថិតក្នុងការស្ទាបស្ទង់មតិនេះ មាន៦៧% បានក្លាយជាស្ត្រីមានផ្ទៃពោះ (ជាបឋមនៅចន្លោះឆ្នាំ១៩៧៨-១៩៧៩) ដែលជាលទ្ធផលបង្កឱ្យមានកំណើតរស់៨០% កំណើតស្លាប់១១% និងរលូត៨% (មិនបង្ខំឬបានបង្កឡើងដោយខ្លួនឯង) (ទំព័រ១៩២)។ "ការសិក្សាបានលាតត្រដាងអំពីនិន្នាការទៅរកកំណើននៃការមានគភ៌ត្រឹមឆ្នាំ១៩៧៨នៅទូទាំងតំបន់នានា" (ទំព័រ៨៧)។ **2. T. de Langis et al.**, *ដូចខ្មោចប្តូរកាយ - ការសិក្សាមួយទៅលើផលប៉ះពាល់ធ្ងន់ធ្ងរនៃអាពាហ៍ពិពាហ៍ដោយបង្ខំ នៅក្រោមរបបខ្មែរក្រហម* (*Like Ghosts Changes Body – A Study on the Impact of Forced Marriage under the Khmer Rouge*), តុលា ២០១៤ - ក្នុងឆ្នាំ២០១៤ (ទំព័រ៤០) ការសិក្សានេះបានសម្ភាសន៍ជាមួយអ្នកឆ្លើយនឹងសំណួរចំនួន១០៦នាក់ ដែលពួកគាត់ជាដើមបណ្តឹងរដ្ឋប្បវេណីនៃសំណុំរឿង០០២ នៅ អ.វ.ត.ក (ទំព័រ១០) និងមកពីខេត្តចំនួន១៥ នៅទូទាំងកម្ពុជានៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (ទំព័រ៤៨)។ ១០៣នាក់ (៩៧%) ក្នុងចំណោមអ្នកឆ្លើយសំណួរទាំងអស់ ដែល៨៣%គឺជាស្ត្រី បានរាយការណ៍ថា ពួកគាត់សុខចិត្តធ្វើតាមការដាក់សម្ពាធនៃអាពាហ៍ដែលមានការរៀបចំ ឬដោយបង្ខំនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ (ទំព័រ៤៤)។ ៨៨.១% បានរាយការណ៍ថា ពួកគាត់មានអារម្មណ៍ថាពួកគាត់ត្រូវបានគេបង្ខំឱ្យរួមភេទបន្ទាប់ពីរៀបការរួច (ទំព័រ៥៤)។ ៧៦% បានរាយការណ៍ថា ពួកគាត់មានកូនដោយសារអាពាហ៍ពិពាហ៍ដោយបង្ខំ (សំគាល់៖ គេមិនច្បាស់ថាតើកូនទាំងនោះចាប់ផ្តើមមានគភ៌នៅពេលណាទេ)។ របកគំហើញគន្លឹះនានាចង្អុលបង្ហាញពីការបន្តពូជដើម្បីបង្កើតចំនួនប្រជាជន គឺជាកត្តាជំរុញមួយនាំឱ្យមានអាពាហ៍ពិពាហ៍ដោយបង្ខំ និងជា "កំណើនដ៏ឆាប់រហ័ស" នៃអាពាហ៍ពាពិហ៍ដោយបង្ខំនៅក្នុងឆ្នាំ១៩៧៨ (ទំព័រ១៤)។ "ជាសំខាន់ អ្នកឆ្លើយនឹងសំណួរក្នុងករណីសិក្សាមួយ បាននិយាយថា មហិច្ឆតានយោបាយរបស់មេដឹកនាំមូលដ្ឋានខ្មែរក្រហម គឺជាការជំរុញឱ្យមានអាពាហ៍ពិពាហ៍ដោយបង្ខំ និងទំនាក់ទំនងសហពន្ធន៍ប្តីប្រពន្ធដោយបង្ខំឱ្យដឹងថា មេដឹកនាំថ្នាក់ខ្ពស់បានដឹង និងបានលើកទឹកចិត្តដល់ការអនុវត្តគោលនយោបាយនេះ" (ទំព័រ១៤)។ ការសិក្សាក៏បានបង្ហាញយ៉ាងទូលំទូលាយផងដែរថា "ការមានគភ៌ គឺជាការភ័យខ្លាចជាប្រចាំសម្រាប់ស្ត្រីទាំងឡាយដែលស្ថិតនៅក្នុងបរិយាកាសនៃការរួចភេទដោយបង្ខំ បូករួមនឹងលក្ខខណ្ឌរស់នៅយ៉ាងអស់សង្ឃឹមដ៏ហួសហេតុ" (ទំព័រ៨០)។ **3. N. Kasumi**, *ហិង្សាដែលមានមូលដ្ឋានលើយ៉េនឌ័រនៅក្នុងសម័យកាលកម្ពុជាប្រជាធិបតេយ្យ រឿងរ៉ាវរបស់អ្នកនៅរស់រានមានជីវិតពីរបបកម្ពុជាប្រជាធិបតេយ្យ (១៩៧៥-១៩៧៩)* (*Gender-Based Violence During the Khmer Rouge Regime: Stories of survivors from the Democratic Kampuchea (1975-1979))*, បោះពុម្ពលើកទីពីរ, មីនា ២០០៨ - របាយការណ៍, ផ្អែកលើបទសម្ភាសន៍នានា គម្រោងសង្ខេបនៃទិន្នន័យបរិមាណ ក្នុងទម្រង់ជាសាច់រឿងរបស់អ្នកនៅរស់រានមានជីវិតនៃអំពើហិង្សាដែលមានមូលដ្ឋានលើយ៉េនឌ័រ រួមទាំងអាពាហ៍ពិពាហ៍ដោយបង្ខំ និងការមានគភ៌ដោយបង្ខំ។ ក្នុងឯកសារបោះពុម្ពលើកទីមួយ (ឆ្នាំ២០០៧), គេបានសម្ភាសន៍មនុស្ស១,៥០០នាក់ ដែលក្នុងចំនួននេះមនុស្ស១០០នាក់ត្រូវបានជ្រើសរើសនូវសាច់រឿងរបស់ពួកគាត់ផ្ទាល់ដើម្បីចងក្រងជាឯកសារ (ទំព័រ៥)។ ក្នុងឯកសារបោះពុម្ពលើកទីពីរ

(២) កាលៈទេសៈដែលនាំឲ្យស្ត្រី និង ក្មេងស្រីត្រូវបានបង្ខំឲ្យក្លាយទៅជា និងនៅតែមាន ផ្ទៃពោះ[27],

(៣) អានុភាពនៃការធ្វើឲ្យមានផ្ទៃពោះដោយបង្ខំមាននៅលើពួកស្ត្រី និង ក្មេងស្រីនៅអំឡុងពេលនៃកម្ពុជាប្រជាធិបតេយ្យ ដោយឡែក ជាលទ្ធផលនៃលក្ខខណ្ឌការងារ និងជីវិតរស់នៅ រួមមាន ម្ហូបអាហារ និងថ្នាំវេជ្ជសាស្ត្រ[28] ហើយនិងអានុភាពដែលវាបន្តមាននៅលើពួកគាត់បច្ចុប្បន្ននេះ,

---

មនុស្ស៦០០បន្ថែមទៀត ត្រូវបានសម្ភាសន៍ដោយនិស្សិតសកលវិទ្យាល័យរបស់អ្នកនិពន្ធប្រហែល២០០នាក់ (ទំព័រ៤)។ ទាក់ទងនឹងការរួមភេទដោយបង្ខំ អ្នកនិពន្ធថ្លែងថា "ក្រោយពិធីរៀបការរួច គូស្រករដែលទើបរៀបការរួចថ្មីៗ ត្រូវបានគេបញ្ជាឲ្យទៅនៅក្នុងខ្ទមតូចមួយ និងដេកជាមួយគ្នានៅពេលយប់។ យោងតាមបទសម្ភាសន៍នានាជាមួយអ្នកទាំងឡាយដែលធ្លាប់ត្រូវបានគេបង្ខំឲ្យរៀបការនៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ [សម័យខ្មែរក្រហម] គូស្រករថ្មីថ្មោងជាញឹកញាប់បាននៅជាមួយគ្នាពីរទៅបីថ្ងៃ រួចហើយក៏បានចេញពីខ្ទមតូចនោះទៅធ្វើការតាមកន្លែងរៀងៗខ្លួន...។ ទាហានខ្មែរក្រហម គឺជាអ្នកដែលត្រូវមកឈ្លបតាមដាននៅជុំវិញផ្ទះរបស់អ្នកដែលទើបរៀបការថ្មី ដើម្បីឲ្យដឹងថាតើពួកគេបានរួមសង្វាសជាមួយគ្នាឬអត់។ បើសិនជាគូស្រករថ្មីថ្មោងនោះមិនអនុវត្តតាមការបញ្ជា នោះពួកគេនឹងត្រូវបញ្ជូនទៅអប់រំ ត្រូវទទួលរងទារុណកម្ម ឬការបំពារបំពានខាងផ្លូវភេទ" (ទំព័រ១៦-១៧)។ ខណៈរបាយការណ៍មិនបានបញ្ចូលសេចក្តីលម្អិតនៃទិន្នន័យទាក់ទងនឹងទីតាំងភូមិសាស្ត្រ ឬការមានគភ៌ចំនួនប៉ុន្មានដែលបានកើតឡើង ដែលបណ្តាលមកពីអាពាហ៍ពិពាហ៍ដោយបង្ខំនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ការរៀបរាប់របស់អ្នករស់រានមានជីវិត គឺវាស្របគ្នាជាទូទៅទៅនឹងរបកគំហើញនៅក្នុងការសិក្សាទាំងពីរខាងលើ ដែលបង្ហាញឲ្យឃើញយ៉ាងទូលំទូលាយនូវនិន្នាការដែលថា ក្រុមមនុស្សប្រុសស្រីដ៏ធំត្រូវបានគេបង្ខំឲ្យរៀបការជាមួយគ្នា និងត្រូវបានគាបសង្កត់ឲ្យរួមសង្វាសជាមួយគ្នាក្នុងរបបកម្ពុជាប្រជាធិបតេយ្យ។

27 អសព សូមជូនសេចក្តីសន្និដ្ឋានថា កាលៈទេសៈដែលស្ត្រី និង ក្មេងស្រី ត្រូវបានបង្ខំឲ្យនៅតែមានផ្ទៃពោះ គឺទាក់ទងនឹងស្ថាន ទម្ងន់ ប៉ុន្តែមិនមែនជាធាតុផ្សំតាមផ្លូវច្បាប់ដែលមានជាប់ជាមួយនឹង "អំពើអមនុស្សធម៌ផ្សេងៗទៀត" នៃការធ្វើឲ្យមានផ្ទៃពោះ ដោយបង្ខំ នោះទេ។

28 សូមមើល ជាឧទាហរណ៍ N. Kasumi, *មាតុភាពនៅក្នុងសង្គ្រាម: ការមានគភ៌នៅក្នុងរបបខ្មែរក្រហម - ប្រវត្តិសាស្ត្រផ្ទាល់មាត់,* *(Motherhood at War: Pregnancy During the Khmer Rouge Regime – Oral History)*, ធ្នូ ២០១៥, ជំពូក៦-៨ និង១០។ H. Ngor ជាមួយ R. Warner, *ការរស់រានមានជីវិតនៅក្នុងវាលពិឃាត (Survival in the Killing Fields)*, ១៩៨៧, ជំពូក២៩៖ ទោះបីជាការមានគភ៌មិនបានកើតឡើងក្នុងបរិបទនៃអាពាហ៍ពិពាហ៍ដោយបង្ខំក៏ដោយ ក៏ជីវប្រវត្តិនេះរៀបរាប់លម្អិតអំពីផលប៉ះពាល់នៃលក្ខខណ្ឌក្នុងការរស់នៅដែលមានចំពោះភរិយារបស់វេជ្ជបណ្ឌិត H. Ngor ដែលបានទទួលមរណភាពក្នុងឆ្នាំ១៩៧៨ ខណៈដែលលោកស្រីកំពុងសម្រាលកូន ក្នុងអំឡុងពេលដែលគ្មានអង្គភាពមើលថែទាំល្អិតល្អន់ គ្មានបន្ទប់វះកាត់។ គ្មានអាហារសម្រាប់ហ៊ួយ (Huoy) ឬកូន ទេ។ ហើយ*ឈ្លប* នៅជុំវិញទីនោះរកមើលបញ្ហា។ នៅក្រោមវិធានសីលធម៌ដ៏តឹងរ៉ឹងរបស់ខ្មែរក្រហម វាជាការហាមឃាត់ចំពោះបុរសមិនឲ្យសម្រាលកូនឲ្យប្រពន្ធរបស់ខ្លួនឡើយ។ បើខ្ញុំសម្រាលកូនដោយខ្លួនឯង អ្នកជិតខាងនឹងដឹង ហើយបើ*ឈ្លប* ដឹងអំពីរឿងនេះ នោះជាចុងបញ្ចប់នៃខ្ញុំ។ ឬបើខ្ញុំធ្វើអ្វីម្យ៉ាងដែលនាំឲ្យគេដឹងថាខ្ញុំជាវេជ្ជបណ្ឌិត នោះក៏ជាចុងបញ្ចប់នៃខ្ញុំដែរ" (ទំព័រ៣៥២)។

(៤) គោលបំណង(នានា)នៃការមានអាពាហ៍ពិពាហ៍ដោយបង្ខំ និងការរួមដំណេកនៅក្នុងអាពាហ៍ពិពាហ៍ដោយបង្ខំ, និង

(៥) នរណាទទួលខុសត្រូវចំពោះការកំណត់ និងការអនុវត្តនូវគោលបំណង(នានា) នៅក្នុងកថាខណ្ឌ១៣(៤)។

១៤. សពអ សូមជូនសេចក្តីសន្និដ្ឋានថា វាមិនមែនរហូតដល់ទីបញ្ចប់នៃកិច្ចស៊ើបសួរចូលទៅក្នុងដីកាសន្និដ្ឋានឲ្យស៊ើបសួរបន្ថែមរបស់ អសព នោះទេ ដែលការកំណត់បទចោទត្រឹមត្រូវបំផុតនៃអង្គហេតុ អាចត្រូវបានកំណត់។ ប៉ុន្តែ សពអ គិតទុកជាមុនថាភស្តុតាងដែលបានមកពីសំនួរ ខាងលើនឹងត្រូវបង្ហាញថា ឧក្រិដ្ឋកម្មដោយឡែកប្រឆាំងនឹងមនុស្សជាតិ នៅក្នុងទម្រង់ "អំពើអមនុស្សធម៌ផ្សេងៗទៀត" បានកើតឡើង ឬមួយក៏ នឹងត្រូវផ្តល់ភស្តុតាងបន្ថែមស្តីពីព្យសនកម្ម ដែលបានរងគ្រោះដោយជនរងគ្រោះពីអាពាហ៍ពិពាហ៍ដោយបង្ខំ និងអំពើរំលោភសេពសន្ថវៈនៅក្នុងអាពាហ៍ពិពាហ៍ដោយបង្ខំ។

## IV. សេចក្តីសន្និដ្ឋាន

១៥. ចំពោះមូលហេតុដូចបានរៀបរាប់នៅខាងលើនេះ សពអ សូមគោរពស្នើសុំឲ្យ កសចស៖

(១) អនុញ្ញាតទទួលយកសំណើសុំឲ្យបំពេញកិច្ចស៊ើបសួររបស់ដើមបណ្តឹងរដ្ឋប្បវេណី, និង

(២) ចាត់ការបំពេញកិច្ចស៊ើបសួរពាក់ព័ន្ធនឹងការធ្វើឲ្យមានផ្ទៃពោះដោយបង្ខំ៕

| កាលបរិច្ឆេទ | ឈ្មោះ | ទីកន្លែង | ហត្ថលេខា |
|---|---|---|---|
| ថ្ងៃទី១ ខែមេសា ឆ្នាំ២០១៦ | **លោក** Nicholas KOUMJIAN<br>សហព្រះរាជអាជ្ញាអន្តរជាតិ | ភ្នំពេញ | |